# សុប្ពជាតក

រៀបរៀងដោយ

*បណ្ឌិត* **គុល ផេង**

សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**
**ព.ស. ២៥៦៤**

| | |
|---|---|
| ឈ្មោះសៀវភៅ | **សុច្ចជជាតក** |
| រៀបរៀងដោយ | បណ្ឌិត **គុល ផេង**<br>ប្រធានពុទ្ធិកបណ្ឌិតសភា<br>នៃសាកលវិទ្យាល័យ<br>បញ្ញាសាស្ត្រកម្ពុជា |
| ទីតាំងធ្វើ | ពុទ្ធិកបណ្ឌិតសភា |
| ការផ្សាយ | របស់ពុទ្ធិកបណ្ឌិតសភា |
| រក្សាសិទ្ធិ | ពុទ្ធិកបណ្ឌិតសភា |
| កាលបរិច្ឆេទ | ថ្ងៃសៅរ៍ ១១ រោច ខែ<br>ស្រាពណ៍ ឆ្នាំជូត<br>ទោស័ក ព.ស. ២៥៦៤<br>ថ្ងៃទី ១៥ ខែ សីហា គ.ស.<br>២០២០ |

# សុច្ចជាតក



ព្រះសាស្ដាកាលស្ដេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា សុច្ចជំ វត ឆច្ចជិ ដូច្នេះជាដើម ។

បានឮថា កុដុម្ពិកៈនោះគិតថា អញនឹងជម្រះបំណុលក្នុងស្រុកមួយ ដូច្នេះហើយ ទើបទៅកាន់ស្រុកដែលគេចំពាក់បំណុលនោះជាមួយភរិយា លុះជម្រះបំណុលរួចហើយ គិតថា អញនឹងយករទេះមកដឹកជាក្រោយ ដូច្នេះហើយ ទើបផ្ញើទុកក្នុងត្រកូលមួយ

ហើយត្រឡប់ទៅកាន់នគរសាវត្ថីវិញ (ពេលធ្វើដំណើរ) បានឃើញភ្នំមួយក្នុងរវាងផ្លូវ ។

ពេលនោះ ភរិយាពោលថា បពិត្រស្វាមី បើភ្នំនេះគប្បីក្លាយជាមាស អ្នកនឹងឲ្យអ្វីដល់ខ្ញុំ ?

កុដុម្ពិកៈពោលថា នាងជាស្អីដែរ យើងនឹងមិនឲ្យអ្វីដល់នាងឡើយ ។

ភរិយាតូចចិត្តថា ស្វាមីរបស់អញមានចិត្តអាក្រក់ណាស់ ដ្បិតថា កាលភ្នំកើតជាមាស ក៏នឹងមិនឲ្យអ្វីដល់អញឡើយ ។

ជនទាំងពីរនាក់ស្វាមីភរិយានោះ ដើរមកជិតដល់វត្តជេតពន គិតថា នឹងផឹកទឹក ដូច្នេះហើយ ទើបចូលទៅក្នុងវត្ត ផឹកទឹក ។ ក្នុងពេលជិតភ្លឺនៅថ្ងៃនោះឯង ព្រះសាស្តាឃើញឧបនិស្ស័យសោតាបត្តិផលរបស់ជនទាំងពីរនោះ កាលព្រះអង្គរង់ចាំការមករបស់

អ្នកទាំងពីរ ទើបទ្រង់គង់ក្នុងបរិវេណព្រះគន្ធកុដិ បញ្ចេញឆព្វណ្ណរង្សីរស្មី ៦ ពណ៌ ។ ចំណែកគូស្វាមីភរិយានោះផឹកទឹកហើយក៏មកថ្វាយបង្គំព្រះសាស្តា រួចអង្គុយក្នុងទីដ៏សមគួរមួយ ។

ព្រះសាស្តាធ្វើបដិសណ្ឋារកិច្ច ហើយត្រាស់សួរថា អ្នកទាំងពីរទៅណាមកណា ?

គូស្វាមីភរិយាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកពីទារបំណុល ក្នុងស្រុកឯណោះ ។

ព្រះសាស្តាត្រាស់សួរភរិយារបស់កុដុម្ពិកៈនោះថា ម្នាលឧបាសិកា ស្វាមីរបស់នាង ប្រាថ្នាប្រយោជន៍ដល់នាង ធ្វើឧបការៈដល់នាងដែរឬ ?

ភរិយាកុដុម្ពិកៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់មានសេចក្តីស្រឡាញ់ ស្វាមីនេះណាស់ ប៉ុន្តែស្វាមីនេះមិនស្រឡាញ់ខ្ញុំម្ចាស់ទេ ថ្ងៃនេះ

កាលខ្ញុំម្ចាស់ឃើញក្អំ ហើយ ពោលថា បើក្អំនេះក្លាយជាមាស អ្នកនឹងឲ្យអ្វីដល់ខ្ញុំ គាត់បែរជាពោលថា នាងជាអ្នកណា យើងនឹងមិនឲ្យអ្វីដល់នាងទេ ស្វាមីនេះជាមនុស្សមានចិត្តអាក្រក់ណាស់ ។

ព្រះសាស្តាត្រាស់ថា ម្នាលឧបាសិកា កុដុម្ពិកៈនេះរមែងពោលយ៉ាងនេះឯង តែកាលណាកុដុម្ពិកៈនេះ រឭកដល់គុណរបស់នាង កាលនោះ រមែងឲ្យឥស្សរិយយសទាំងពួងដល់នាង ។

កាលកិរិយារបស់កុដុម្ពិកៈនោះក្រាបបង្គំទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គត្រាស់សម្តែង ទើបព្រះសាស្តានាំយករឿងក្នុងអតីតមកសម្តែងដូចតទៅថា

ក្នុងអតីតកាលដ៏យូរលង់ណាស់ទៅហើយ កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរ

ពារាណសី, ព្រះពោធិសត្វជាអាមាត្យអ្នកសម្រេចរាជកិច្ចទាំងអស់របស់ព្រះបាទព្រហ្មទត្តនោះ ។ សម័យថ្ងៃមួយ ព្រះរាជាឃើញព្រះឱរសដែលជាឧបរាជមកកាន់ទីបម្រើ ទ្រង់ព្រះតម្រិះថា បុត្រនេះគប្បីបង្កនូវភ័យខាងក្នុង ដូច្នេះហើយ ទើបត្រាស់ឲ្យហៅព្រះរាជ ឱរសនោះមក ហើយត្រាស់ថា នែបុត្រ ដរាបណាបិតានៅមានជីវិត បុត្រកុំនៅក្នុងនគរនេះឡើយ ចូរបុត្រទៅនៅក្នុងទីដទៃ អំណើះឥតអំពីបិតាទៅ សឹមបុត្រមកគ្រប់គ្រងរាជសម្បត្តិចុះ។ ព្រះរាជបុត្រទទួលព្រះរាជបញ្ជាថា ល្អ រួចថ្វាយបង្គំលាព្រះរាជបិតា ព្រះអង្គនិងជេដ្ឋជាយា ចេញចាកនគរទៅកាន់ជាយដែន សាងបណ្ណសាលានៅក្នុងព្រៃ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយផ្លៃឈើតូចធំក្នុងព្រៃ ។

ចំណេរកាលតមក ព្រះរាជាជាបិតាក៏សោយទិវង្គត ។ ព្រះរាជបុត្រពិនិត្យមើលផ្កាយ នក្ខត្តឫក្ស

ដឹងថា ព្រះបិតាសោយទិវង្គតហើយ ទើបមកកាន់នគរពារាណសី ក្នុងរវាងផ្លូវបានឃើញភ្នំមួយ ។

លំដាប់នោះ ព្រះជាយាសួរថា បពិត្រព្រះសម្មតិទេព បើភ្នំនេះ គប្បីក្លាយជាមាស ទ្រង់នឹងប្រទានអ្វីដល់ខ្ញុំម្ចាស់ ?

ព្រះរាជបុត្រត្រាស់ថា នាងជានរណា យើងនឹងមិនឲ្យអ្វីមួយឡើយ ។

ព្រះជាយាតូចព្រះទ័យថា អញមិនបោះបង់ព្រះអង្គ ព្រោះសេចក្តីស្នេហាក្នុងព្រះស្វាមីនេះ ទើបចូលទៅកាន់ព្រៃជាមួយ ប៉ុន្តែស្វាមីនេះ ត្រាស់យ៉ាងនេះ ទ្រង់ជាអ្នកមានព្រះហឫទ័យអាក្រក់ណាស់ កាលទ្រង់បានជាព្រះរាជាហើយ តើនឹងធ្វើសេចក្តីល្អដល់អញដូចម្តេចកើត ។

ព្រះរាជបុត្រនោះយាងមក ទ្រង់គ្រងរាជសម្បត្តិហើយ ទ្រង់តែងតាំងព្រះជាយានោះ ទុកក្នុងតំណែងអគ្គមហេសី ទ្រង់ប្រទានត្រឹមតែយសនេះប៉ុណ្ណោះ ចំណែកការរាប់អាន ការលើកតម្កើងឲ្យក្រៃលែងឡើងទៅទៀត មិនមាន សូម្បីភាពដែលព្រះនាងមាននៅ ក៏ទ្រង់មិនដាក់ព្រះទ័យ ( គិតថាមាន ) ។

ព្រះពោធិសត្វគិតថា ព្រះទេវីនេះមានឧបការៈចំពោះព្រះរាជា មិនអើពើដល់សេចក្តីលំបាក បានយាងទៅនៅព្រៃជាមួយ ប៉ុន្តែព្រះរាជានេះទ្រង់មិនគិតដល់ព្រះទេវីសោះ គិតតែ ត្រេកអរជាមួយនឹងស្នំដទៃអញនឹងធ្វើដោយប្រការដែលព្រះទេវីនេះ បានឥស្សរិយៈទាំងពួង ដូច្នេះហើយ ថ្ងៃមួយ ចូលគាល់ព្រះទេវីហើយពោលថា បពិត្រព្រះទេវី ទូលបង្គំមិនបានសូម្បីត្រឹមតែដុំបាយអំពីសម្នាក់ព្រះនាង ព្រោះហេតុអ្វី ទើប

ព្រះនាងមិននឹកនាទូលបង្គំ ព្រះនាងមានព្រះហឫទ័យអាក្រក់ក្រៃពេក ។

ព្រះទេវីមានព្រះសវនីយ៍ថា បពិត្រលោកឪពុក បើខ្លួនខ្ញុំបាន ខ្ញុំក៏នឹងឲ្យលោក ប៉ុន្តែកាលខ្ញុំមិនបាន នឹងឲ្យលោកបានដូចម្តេចកើត ឥឡូវនេះ ព្រះរាជានឹងប្រទានដល់ខ្ញុំដូចម្តេច (ព្រោះថា) មកតាមផ្លូវ កាលខ្ញុំពោលថា បើក្អមនេះក្លាយជាមាស ព្រះអង្គនឹងប្រទានអ្វីដល់ខ្ញុំម្ចាស់ខ្លះ ព្រះរាជាទ្រង់ត្រាស់ថា នាងជាអ្នកណា យើងនឹងមិនឲ្យអ្វីឡើយ សូម្បីរបស់ដែលបរិច្ចាគបានងាយ ក៏ទ្រង់មិនបរិច្ចាគ ។

ព្រះពោធិសត្វសួរថា តើព្រះនាងអាចពោលពាក្យនេះ ក្នុងសម្នាក់ព្រះរាជាដែរឬទេ ?

ព្រះទេវីពោលថា បពិត្រលោកឪពុក ខ្ញុំអាចពោលបាន ។

ព្រះពោធិសត្វពោលថា បើដូច្នោះ កាលទូលបង្គំនៅក្នុងសម្នាក់របស់ព្រះរាជា នឹងទូលសួរ ព្រះនាងគប្បីពោលចុះ ។

ព្រះទេវីទទួលថា ប្រពៃហើយ លោកឪពុក ។

កាលដែលព្រះទេវីទៅគាល់ព្រះរាជា ហើយប្រថាប់ឈរ ព្រះពោធិសត្វសួរថា បពិត្រព្រះនាងម្ចាស់ ខ្ញុំមិនបានរបស់ណាមួយអំពីសម្នាក់ព្រះនាងមិនមែនឬ ?

ព្រះទេវីត្រាស់ថា បពិត្រលោកឪពុក ប្រសិនបើខ្ញុំបាន ខ្ញុំនឹងឲ្យលោក ប៉ុន្តែខ្ញុំក៏មិនបានរបស់ណាមួយឡើយ បើខ្ញុំមិនបានផង នឹងឲ្យលោកបានដូចម្ដេចឥឡូវនេះ តើព្រះរាជានឹងឲ្យខ្ញុំដូចម្ដេចកើត ព្រោះថាកាលមកអំពីព្រៃ ព្រះរាជានោះទ្រង់ឃើញភ្នំមួយកាលខ្ញុំទូលសួរថា បើភ្នំនេះគប្បីក្លាយជាមាស ព្រះអង្គ

នឹងប្រទានអ្វីដល់ខ្ញុំម្ចាស់ខ្លះ ព្រះរាជាទ្រង់ត្រាស់ថា នាងជានរណា យើងនឹងមិនឲ្យអ្វីដល់នាងឡើយ សូម្បីរបស់ដែលលះបង់បានងាយ ក៏ទ្រង់មិនលះបង់ កាលនឹងសម្តែងសេចក្តីនេះ ទើបពោលគាថាទី ១ ថា

**សុច្ចជំ វត ឆច្ចជិ,**
**វាចាយ អទទំ គិរឹ;**
**តាំញ្ញ៉ិ តស្សុចជន្តស្ស,**
**វាចាយ អទទ បព្ពតំ ។**

ព្រះរាជាកាលមិនប្រទានភ្នំ (សូម្បី)ដោយព្រះវាចា ឈ្មោះថាមិនលះបង់នូវរបស់ដែលគួរលះបង់ដោយងាយទេ ប្រសិនបើព្រះរាជាបានប្រទានភ្នំ (សូម្បី) ដោយព្រះវាចាព្រះរាជានោះ (ដែលខ្ញុំសូមហើយ) គង់លះបង់វត្ថុខ្លះ ។

*ព្រះរាជាស្តាប់ពាក្យនោះហើយ ត្រាស់គាថាទី ២ ថា*

**យញ្ហិ កយិរា តញ្ហិ វទេ,**
**យំ ន កយិរា ន តំ វទេ;**
**អករោន្តំ ភាសមានំ,**
**បរិជានន្តិ បណ្ឌិតា។**

*បុគ្គលធ្វើអំពើណា គប្បីនិយាយអំពើនោះ មិនធ្វើអំពើណា មិនគប្បីនិយាយអំពើនោះ ពួកបណ្ឌិតរមែងកំណត់ដឹងនូវបុគ្គលដែលមិនធ្វើ (គ្រាន់តែ) និយាយ ។*

*ព្រះទេវីស្តាប់ពាក្យនោះហើយ ផ្គងអញ្ជលី ពោលគាថាទី ៣ ថា*

រាជបុត្ត នមោ ត្យត្ថុ,
សច្ចេ ធម្មេ ឋិតោ ចសិ;
យស្ស តេ ព្យសនំ បត្តោ,
សច្ចស្មឹ រមតេ មនោ។

*បពិត្រព្រះរាជបុត្រ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ដែលឋិតនៅក្នុងវចីសច្ចៈផង ក្នុងសភាវធម៌ផង សូម្បីដល់នូវសេចក្តីវិនាស ក៏ព្រះហឬទ័យ របស់ព្រះអង្គនៅតែត្រេកអរក្នុងសច្ចៈ ។*

*ព្រះពោធិសត្វស្តាប់ពាក្យ ដែលព្រះទេវីពោលគុណកថា របស់ព្រះរាជាយ៉ាងនេះហើយ កាលនឹងសរសើរគុណកថារបស់ព្រះទេវី ទើបពោលគាថាទី ៤ ថា*

យា ទលិទ្ទី ទលិទ្ទស្ស,
អឌ្ឍា អឌ្ឍស្ស កិត្តិម;
សា ហិស្ស បរមា ភរិយា,
សហិរញ្ញស្ស ឥត្ថិយោ ។

*ភរិយាណារបស់ប្តីអ្នកទ័លក្រ ក៏ជាស្រីទ័លក្រដែរ របស់ប្តីអ្នកស្តុកស្តម្ភ ក៏ជាស្រីស្តុកស្តម្ភ មានកេរ្តិ៍ឈ្មោះដែរ ភរិយានោះឈ្មោះថាជាភរិយាដ៏ឧត្តមរបស់ប្តីនោះ ស្រីទាំងឡាយរបស់អ្នកមានប្រាក់ (ក៏ដូច្នោះដែរ) ។*

*ព្រះពោធិសត្វពោលយ៉ាងនេះហើយ ក៏ពោលគុណរបស់ព្រះទេវីដល់ព្រះរាជាថា បពិត្រមហារាជព្រះទេវីនេះ កាលព្រះអង្គមានសេចក្តីទុក្ខនៅក្នុងព្រៃព្រះនាងក៏ជាអ្នកមានសេចក្តីទុក្ខដែរ ព្រះអង្គគួរធ្វើ*

សេចក្ដីរាប់អានដល់ព្រះទេវីនោះ ។ ព្រះរាជារលឹក
គុណព្រះទេវីតាមពាក្យព្រះពោធិសត្វ ទ្រង់ត្រាស់ថា
នែបណ្ឌិត យើងរលឹកគុណព្រះទេវីតាមពាក្យរបស់
លោក ដូច្នេះហើយទ្រង់ប្រទានឥស្សរិយយសទាំងពួង
ដល់ព្រះទេវី ។ រួចហើយទ្រង់ត្រាស់ថា លោកបានឲ្យ
យើងរលឹកគុណព្រះទេវី ដូច្នេះហើយ បានធ្វើសក្ការដ៏
ធំសូម្បីដល់ព្រះពោធិសត្វ ។

ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ
ទ្រង់ប្រកាសសច្ចធម៌ និងប្រជុំជាតក កាលចប់សច្ចធម៌
គូស្វាមីភរិយាបានតាំងនៅក្នុងសោតាបត្តិផល ។

តទា ពារាណសិរាជា អយំ កុដុម្ពិកោ
អហោសិ ព្រះបាទពារាណសីក្នុងកាលនោះ បាន
មកជាកុដុម្ពិកៈនេះ។

ទេវី អយំ ឧបាសិកា ព្រះទេវីបានមកជា
ឧបាសិកានេះ

បណ្ឌិតាមច្ចោ បន អហមេវ អហោសិំ
ចំណែកអាមាត្យជាបណ្ឌិតគឺតថាគតនេះឯង ។

សុច្ចជជាតក ចប់ ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត
បុចិមន្ទវគ្គ សុច្ចជជាតក បិដកលេខ ៥៨ ទំព័រ ២០៦-២០៧)

ដោយជាតកភាណក